**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តសៀមរាប**

សាលក្រមលេខ: **៣៤ (៥)/ ៤៣៨**

ចុះថ្ងៃទី២៩ ខែ វិច្ឆិកា ឆ្នាំ២០២៣

*រឿងក្តីរដ្ឋប្បវេណីលេខ ៩៤២ ចុះថ្ងៃទី១៩ ខែ កញ្ញា ឆ្នាំ២០២៣*

*ប្រភេទនៃរឿងក្តី ៖ **បណ្តឹងសុំលែងលះ***

*បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នាថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៣*

*ថ្ងៃខែឆ្នាំប្រកាសសាលក្រម: ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ២០២៣*

## តាងនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តសៀមរាប

## ចៅក្រមជំនុំជម្រះ

-លោក [redacted] ជាចៅក្រម នៃសាលាដំបូង ខេត្តសៀមរាប

-លោក [redacted] ជាក្រឡាបញ្ជី នៃសាលាដំបូង ខេត្តសៀមរាប

បានចេញសាលក្រមដែលមានភាគី៖

**ដើមចោទ៖**

-ឈ្មោះ [redacted] លីនណារ៉ូ ភេទស្រី កើតឆ្នាំ១៩៨២ អាសយដ្ឋាននៅភូមិ [redacted] ។ វត្តមាន

មានលោក [redacted] ជាអ្នកតំណាងដោយអាណត្តិឲ្យដើមចោទ ។ វត្តមាន

**ចុងចម្លើយ ៖**

-ឈ្មោះ [redacted] ឆវ័ន្ត ភេទប្រុស កើតឆ្នាំ១៩៨៣ អាសយដ្ឋាននៅ [redacted] ។ អវត្តមាន

មានលោក [redacted] ជាអ្នកតំណាងដោយអាណត្តិឲ្យចុងចម្លើយ ។ វត្តមាន

## អង្គហេតុ និង ចំណុចខាងច្បាប់

១-សាលក្រមដែលទាមទារដោយដើមចោទ

<u>ការទាមទាររបស់ដើមចោទ៖</u>

១-លែងលះរវាងដើមចោទឈ្មោះ [redacted] លីនណារ៉ូ និងចុងចម្លើយឈ្មោះ [redacted] ឆវ័ន្ត ។

២-កំណត់ថាដើមចោទឈ្មោះ [redacted] លីនណារ៉ូ ជាអ្នកមានអំណាចមេបាលើកូនឈ្មោះ [redacted] ម៉ាណា ភេទស្រី កើតថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៣ ដែលជាកូនរវាងដើមចោទ និងចុងចម្លើយ ។

៣- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

<u>ចម្លើយតបរបស់ចុងចម្លើយ៖</u>

-ឯកភាពតាមការទាមទាររបស់ដើមចោទ ។



Scanned with CamScanner

២-ការសង្ខេបរឿង ៖

គូភាគីបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាជាប្តីប្រពន្ធ ត្រឹមត្រូវតាមច្បាប់ មានសំបុត្រអាពាហ៍ពិពាហ៍លេខ៖ ១៥៦ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៤ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំសាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ។ ជាចំណងដៃអាពាហ៍ពិពាហ៍ គូភាគីមានកូនចំនួន ១នាក់ឈ្មោះ [redacted] ម៉ាណា ភេទស្រី កើតថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៣ ។ មូលហេតុនៃការលែងលះ ដោយការរស់នៅជាមួយគ្នាកន្លងមក មិនមានភាពចុះសម្រុងជាមួយគ្នា ដែលជាហេតុធ្វើឲ្យគូភាគីអស់មនោសញ្ចេតនាជាប្តីប្រពន្ធនិងគ្នាតទៅទៀត ដោយមានការប្រច័ណ្ឌ និងប្រកាន់គ្នាទៅវិញទៅមក ។ គូភាគីពុំមិនមានទ្រព្យសម្បត្តិរួម និងបំណុលរួមនោះទេ ។

៣-ចំណុចគ្មានវិវាទ ៖

-គូភាគីព្រមព្រៀងលែងលះ

-គូភាគីប្រគល់សិទ្ធអំណាចមេបាទៅឲ្យដើមចោទលើកូន

-ដើមចោទបានព្រមព្រៀងទទួលប្រាក់អាហារកាតព្វកិច្ចចំនួន ១៥០$ ក្នុងមួយខែពីចុងចម្លើយ

៤-ចំណុចមានវិវាទ ៖ គ្មាន

## សំអាងហេតុ

តាមលទ្ធផលនៃការសាកសួរសាមីភាគី និងពិនិត្យភស្តុតាង នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ឃើញថា ៖

គូភាគីបានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាជាប្តីប្រពន្ធ ត្រឹមត្រូវតាមច្បាប់ មានសំបុត្រអាពាហ៍ពិពាហ៍លេខ៖ ១៥៦ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៤ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំសាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ។ ជាចំណងដៃអាពាហ៍ពិពាហ៍ គូភាគីមានកូនចំនួន ១នាក់ឈ្មោះ [redacted] ម៉ាណា ភេទស្រី កើតថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៣ ។ មូលហេតុនៃការលែងលះ ដោយការរស់នៅជាមួយគ្នាកន្លងមក មិនមានភាពចុះសម្រុងជាមួយគ្នា ដែលជាហេតុធ្វើឲ្យគូភាគីអស់មនោសញ្ចេតនាជាប្តីប្រពន្ធនិងគ្នាតទៅទៀត ដោយមានការប្រច័ណ្ឌ និងប្រកាន់គ្នាទៅវិញទៅមក ។ គូភាគីពុំមិនមានទ្រព្យសម្បត្តិរួម និងបំណុលរួមនោះទេ ។

ដើមចោទឈ្មោះ [redacted] លីនណារ៉ូ បានធ្វើសេចក្តីថ្លែងការណ៍បញ្ជាក់នៅគ្រប់នីតិវិធីថា៖ ខ្លួនសុំលែងលះពីចុងចម្លើយដោយមូលហេតុថា ចុងចម្លើយរឹតត្បិតសេរីភាពខ្លួននិងមានការប្រច័ណ្ឌច្រើនព្រមទាំងតាមរករឿងដល់កន្លែងធ្វើការរបស់ខ្លួន ធ្វើឲ្យខ្លួនបាត់បង់កិត្តិយស និងសេចក្តីថ្លៃថ្នូរ ។ ចុងចម្លើយតែងប្រើហិង្សានៅពេលឈ្លោះគ្នាម្តងៗតែងបោកប្រាស់របស់របរសម្ភារៈប្រើប្រាស់ផ្សេងៗ ហើយពេលឈ្លោះគ្នាម្តងៗខ្លួនបានហាមឃាត់មិនអោយឈ្លោះគ្នា ព្រោះជាពេលយប់វិខានដំណេកកូន តែចុងចម្លើយមិនស្តាប់ហើយបានយកកូនមកអោយចូលរួមដឹងលឺពេលឈ្លោះប្រកែកគ្នាថែមទៀត ។ ចំពោះរឿងសេដ្ឋកិច្ចចុងចម្លើយមិនបានផ្គត់ផ្គង់គ្រួសារអោយបានគ្រប់គ្រាន់នោះទេ គាត់ផ្គត់ផ្គង់ក្នុងមួយខែចំនួន ២០០$ សល់ប៉ុន្មានខ្លួនជាអ្នករ៉ាប់រងគ្រប់យ៉ាងដូចជា ការចំណាយនៅក្នុងផ្ទះនិងចំណាយលើសាលាកូន និងសម្លៀកបំពាក់កូន

គ្រប់យ៉ាងដោយការរ៉ាប់រងចំណាយមិនគ្រប់ខ្លួនបានសុំជំនួយពីឪពុកម្តាយខ្លួនជារៀងរាល់ខែ ។ មូលហេតុមួយទៀត ដែលធ្វើអោយខ្លួនអស់ចិត្តពីចុងចម្លើយគឺគាត់បានប្រមាថមើលងាយខ្លួនថា ខ្លួនមានសាហាយក្បត់គាត់និងបានអោយខ្លួនស្បថនៅចំពោះមុខព្រះអង្គចេក ព្រះអង្គចម ។ មូលហេតុទាំងនេះទើបខ្លួនសុំលែងលះពីចុងចម្លើយ និងសុំសិទ្ធអំណាចមេបាលើកូនឈ្មោះ [redacted] ម៉ាណា កើតថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០១៣ ដោយហេតុថាខ្លួនមានលទ្ធភាពចិញ្ចឹមកូន ព្រោះខ្លួនជាអាជីវករលក់ដូរនៅក្នុងផ្សារនិងមានការងារក្រៅម៉ោងដែលអាចមានលទ្ធភាពចិញ្ចឹមកូនគ្រប់គ្រាន់ ជាពិសេសខ្លួនមានពេលវេលាមើលថែកូនទាំងនៅផ្ទះ និងនៅសាលា និងផ្តល់ភាពកក់ក្តៅដល់កូនគ្រប់គ្រាន់ ។ ខ្លួនទាមទារប្រាក់អាហារកាតព្វកិច្ចចិញ្ចឹមកូនចំនួន ១៥០$ ក្នុងមួយខែ រហូតដល់កូនពេញវ័យនីតិភាព ។

-លោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឲ្យដើមចោទធ្វើសេចក្តីថ្លែងការណ៍ថា៖ ខ្លួនសុំរក្សាសេចក្តីថ្លែងការណ៍ដូចក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងសេចក្តីថ្លែងការណ៍របស់ដើមចោទ ទុកជាបានការដដែល ។

-លោកមេធាវី [redacted] ជាអ្នកតំណាងដោយអាណត្តិឲ្យចុងចម្លើយ ធ្វើសេចក្តីថ្លែងការណ៍ថា ៖ កូនក្តីរបស់ខ្លួនបានឯកភាពព្រមព្រៀងតាមការទាមទាររបស់ដើមចោទគ្រប់ចំណុច ដូចខាងក្រោម៖

. ព្រមព្រៀងលែងលះពីដើមចោទ

. ព្រមព្រៀងប្រគល់សិទ្ធអំណាចមេបាទៅអោយដើមចោទ

. ព្រមព្រៀងបង់ប្រាក់អាហាកាតព្វកិច្ចចិញ្ចឹមកូនក្នុងមួយខែ ១៥០$ ឲ្យទៅដើមចោទ

-ដើមចោទឈ្មោះ [redacted] លីនណារ៉ូ និងចុងចម្លើយឈ្មោះ [redacted] ឆវ័ន្ត បានធ្វើសេចក្តីថ្លែងការណ៍បញ្ជាក់នៅគ្រប់នីតិវិធីថា ការរស់នៅមិនចុះសម្រុងគ្នា ដោយមូលហេតុថាមិនយល់អំពីគ្នាទៅវិញទៅមក ហើយតែងឈ្លោះប្រកែកគ្នាជាញឹកញាប់ ។ ដូច្នេះ ទើបដើមចោទសុំលែងលះពីចុងចម្លើយ ដូចមាននៅក្នុងកម្មវត្ថុនៃបណ្តឹងចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣ ហើយគូភាគីឯកភាពដូចនៅក្នុងកម្មវត្ថុនៃបណ្តឹង ខាងលើ ។

-យល់ឃើញថា ឆ្លងតាមការធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ការធ្វើសេចក្តីថ្លែងការណ៍របស់ភាគីដើមចោទ អាចបញ្ជាក់បានថា សហព័ទ្ធបានរស់នៅមិនចុះសម្រុងនឹងគ្នា ហើយតែងតែមានរកាំរកូសជាមួយគ្នាជាញឹកញាប់ ធ្វើឱ្យដើមចោទអស់មនោសញ្ចេតនាមិនអាចរស់ជាប្តីប្រពន្ធ ជាមួយនឹងចុងចម្លើយតទៅទៀតបាន ដែលជាបញ្ហាប្រឈម ធ្វើឲ្យចំណងអាពាហ៍ពិពាហ៍ត្រូវបានបែកបាក់ ហើយក៏គ្មានលទ្ធផលនឹងសង្ឃឹមថា នឹងអាចធ្វើបដិទានឡើងវិញបាន ដូច្នេះ តុលាការគប្បីពិចារណាលើការសុំលែងលះរបស់ភាគីដើមចោទ តាមមាត្រា ៩៧៨ នៃក្រមរដ្ឋប្បវេណី ។

-យល់ឃើញថា ដើមចោទបានសុំឲ្យខ្លួនជាអ្នកមានសិទ្ធិអំណាចមេបាលើកូនឈ្មោះ ផ្លុង ម៉ាណា ភេទស្រី កើតថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៣ និងដោយមានការឯកភាពពីចុងចម្លើយ ដូច្នេះតុលាការគប្បីពិចារណាតាមការស្នើសុំរបស់ដើមចោទ។

-យល់ឃើញថាការទាមទារអាហារកាតព្វកិច្ចចិញ្ចឹមកូនគឺគូភាគីបានឯកភាពគ្នា ដូច្នេះគប្បីសម្រេចតាមការទាមទារ ។



Scanned with CamScanner

-គូភាគី អះអាងថា ៖ ទ្រព្យសម្បត្តិរួម និងបំណុលរួម គ្មានទេ ។

-សរុបសេចក្តីមក ឆ្លងតាមការពិនិត្យលើភស្តុតាងជាឯកសារនៅក្នុងសំណុំរឿង, ការធ្វើសេចក្តីថ្លែងការណ៍របស់គូភាគីនៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការទាញហេតុផលដោយផ្ទាល់មាត់រួចមក ឃើញថាដើមចោទស្នើសុំតុលាការលែងលះពីចុងចម្លើយ ចំណែកចុងចម្លើយបានបានព្រមព្រៀងលែងលះផងដែរ ដូច្នេះគប្បីតុលាការធ្វើការវិនិច្ឆ័យសម្រេចសេចក្តីទៅតាមច្បាប់ជាធរមាន ។

-ចំពោះប្រាក់ប្រដាប់ក្តីនឹងអនុវត្តតាមមាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី តែដើមចោទស្នើសុំជាអ្នកទទួលបន្ទុក ហេតុនេះគប្បីតុលាការសម្រេចតាមការស្នើសុំរបស់ដើមចោទ។

## សេចក្តីសម្រេចបញ្ចប់៖

I.ឲ្យដើមចោទឈ្មោះ [redacted] លីនណារ៉ូ ភេទស្រី កើតឆ្នាំ១៩៨២ សញ្ជាតិខ្មែរ និងចុងចម្លើយឈ្មោះ [redacted] ឆវ័ន្ត ភេទប្រុស កើតឆ្នាំ១៩៨៣ សញ្ជាតិខ្មែរ លែងលះបញ្ឈប់ការរួមរស់បែបនីតិសង្វាសពីគ្នា ចាប់ពីពេលប្រកាសសាលក្រមនេះតទៅ។

II.ឲ្យដើមចោទឈ្មោះ [redacted] លីនណារ៉ូ ស្ថិតនៅក្នុងភាពម៉េម៉ាយកំណត់រយៈពេល១២០ថ្ងៃ ចាប់ពីថ្ងៃបានទទួលដំណឹងអំពីសាលក្រមនេះ តាមមាត្រា៩៥០ នៃក្រមរដ្ឋប្បវេណី។

III.ប្រគល់សិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted] ម៉ាណា ភេទស្រី កើតថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៣ ឲ្យទៅម្តាយឈ្មោះ [redacted] លីនណារ៉ូ ជាអ្នកមានសិទ្ធិអំណាចមេបាចិញ្ចឹមបីបាច់ថែរក្សាកូន ។ បង្គាប់ឲ្យដើមចោទឈ្មោះ [redacted] លីនណារ៉ូ ត្រូវបង្កលក្ខណៈងាយស្រួលដល់ចុងចម្លើយឈ្មោះ [redacted] ឆវ័ន្ត ក្នុងការទៅចូលជួបនិងប្រាស្រ័យទាក់ទងជាមួយកូន តាមមាត្រា១០៤០ នៃក្រមរដ្ឋប្បវេណី ។

IV.បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] ឆវ័ន្ត បង់អាហារកាតព្វកិច្ចចិញ្ចឹមកូនទៅឲ្យដើមចោទឈ្មោះ [redacted] លីនណារ៉ូ ក្នុងមួយខែៗកំណត់ចំនួន ១៥០$ (មួយរយហាសិបដុល្លារ) អាមេរិក រហូតដល់កូនពេញវ័យនីតិភាព ។

V.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

សាលក្រមនេះទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី២២ ខែ វិច្ឆិកា ឆ្នាំ២០២៣ ចំពោះមុខគូភាគី និងប្រកាសជាសាធារណៈ នៅថ្ងៃ ពុធ ២រោច ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃ២៩ ខែ វិច្ឆិកា ឆ្នាំ២០២៣ ។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខានិងត្រា: [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ២រោច ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ពស .២៥៦៧

សៀមរាប,ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

ចៅក្រមជំនុំជម្រះ

[redacted]



Scanned with CamScanner